01739942

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)

# គម្រោងបញ្ចប់ផែនការ

# កំណែលើកទី ១៣

# ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧


**សេចក្តីសង្ខេប** ..... 3

I. **សេចក្តីផ្តើម** ..... 4

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** ..... 9

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** ..... 12

ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត ..... 12

ខ. អង្គបុរេជំនុំជម្រះ ..... 16

IV. **ផែនការបញ្ចប់សវនាការ** ..... 17

ក. សំណុំរឿង០០២/០២ ..... 18

ខ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ ..... 22

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** ..... 22

ក. សំណុំរឿង០០២/០២ ..... 22

ខ. សំណុំរឿង០០៣/០០៤ ..... 23

VI. **សេចក្តីសន្និដ្ឋាន** ..... 23

ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ។


**សំគាល់៖**

គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានកែសម្រួលរៀងរាល់មួយត្រីមាសម្តង ក្នុងគោលបំណងរៀបចំផែនការ។ មាតិកានៃគម្រោងនេះរួមមានការប៉ាន់ប្រមាណនូវពេលវេលាសម្រាប់សំណុំរឿងដែលនៅសេសសល់នៃ អ.វ.ត.ក. គិតត្រឹមពេលនៃការកែសម្រួលនេះ។ កត្តាមួយចំនួន ក្នុងនោះរួមមានការវិវត្តនៃដំណើរការនីតិវិធី គឺអាចមានឥទ្ធិពលទៅលើការប៉ាន់ប្រមាណទុកទាំងនេះ។ ហេតុដូច្នេះពេលវេលាដែលគ្រោងទុកទាំងឡាយមិនផ្ទុះបញ្ចាំងតម្រូវការតាមផ្លូវច្បាប់ទៅលើព្រឹត្តិការណ៍សំខាន់ខុសៗគ្នានឹងត្រូវសម្រេចនៅពេលណានោះឡើយ។ គម្រោងបញ្ចប់ផែនការ អ.វ.ត.ក. ត្រូវបានរៀបចំនិងចេញដោយការិយាល័យរដ្ឋបាល ដោយមានការចូលរួមយោបល់ពីការិយាល័យតុលាការទាំងអស់។

01739944

## សេចក្តីសង្ខេប


គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អង្គជំនុំជម្រះ") ត្រូវបានរៀបចំឡើងជាលើកដំបូងនៅខែមីនា ឆ្នាំ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យរដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះផ្សេងៗ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាការធ្វើបច្ចុប្បន្នភាពប្រចាំត្រីមាសទី១៣ នៃ គម្រោងបញ្ចប់ផែនការនេះដែលបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។

នៅក្នុងត្រីមាសនេះ ភាគីក្នុងសំណុំរឿង ០០២/០២ បានដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើទាមទារសំណងចុងក្រោយរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីនានា ចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧ ហើយបន្ទាប់មក អង្គជំនុំជម្រះបានផ្អាកកិច្ចដំណើរការនីតិវិធីដើម្បីពិភាក្សាសម្រេចអំពីសាលក្រម និងធ្វើសេចក្តីព្រាងសាលក្រម។

នៅក្នុងកំឡុងពេលត្រីមាសនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ជាលើកទីពីរ បន្ទាប់ពីបំពេញកិច្ចស៊ើបសួរបន្ថែម ដែលភាគីនានាបានស្នើសុំ។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរួមគ្នា ដោយស្នើសុំឱ្យសហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួនក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន។ ពួកគាត់ក៏បានជូនដំណឹងរួមគ្នាផងដែរអំពីការបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹងជននេះ។ នៅចុងខែ មិថុនា សហចៅក្រមស៊ើបអង្កេតបានរៀបចំបញ្ចប់សំអាងហេតុសម្រាប់ដីកាដំណោះស្រាយផ្នែកសម្រេចសេចក្តី ដោយលើកលែងការចោទប្រកាន់លើ អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤/០១[1]។

លំហូរនៃគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។


---

[1] ដីកាដំណោះស្រាយដែលមានសំអាងហេតុពេញលេញបានចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧។

## I. សេចក្ដីផ្ដើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្ដើមដំណើរការរបស់ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្ដី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៧៩”[2]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងបរិបទនៃសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀត បានកំណត់អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ។ ឯកសារនេះធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អង្គជំនុំជម្រះវិសាមញ្ញ ធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី១៣ ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែតម្រូវដែលចាំបាច់នានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី ១ ខែ មេសា ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៧។

៣ ឯកសារនេះផ្ដោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងដែលនៅសេសសល់ទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្ដល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្ដី ព្រមទាំង

[2] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

ស្ថានភាពនៃសំណុំរឿងទាំងនោះ ព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិននឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ បញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។ សហព្រះរាជអាជ្ញាបានថ្លែងជាសាធារណៈថា នឹងពុំមានសំណុំរឿងបន្ថែមទៀតទេ បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤[3]។ ហេតុនេះ សំណុំរឿងដែលមាននាពេលនេះគឺជាសំណុំរឿងសរុបដែល អ.វ.ត.ក. ត្រូវចាត់ការតាមនីតិវិធី។

៤ សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេចអ៊ាវ (ហៅ ឌុច) គឺជាសំណុំរឿងដំបូងដែលជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះ អ.វ.ត.ក. ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសសាលដីការបស់ខ្លួននៅក្នុងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ធ្វើឲ្យសំណុំរឿងនេះត្រូវបានបញ្ចប់ស្ថាពរ។ កាំង ហ្គេចអ៊ាវ ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

៥ អង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗចំនួនពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយដែលអង្គជំនុំជម្រះវិសាមញ្ញកំណត់ឈ្មោះសំណុំរឿងថា សំណុំរឿង០០២/០១ នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន។ ជនជាប់ចោទពីរនាក់ទៀតនៅក្នុងរឿងក្ដី គឺ អៀង សារី និង អៀង ធីរិទ្ធ បានទទួលមរណភាពនៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ហេតុនេះហើយ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងពួកគេត្រូវបានរំលត់។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន និង នួន ជា មានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និងត្រូវបានផ្ដន្ទាទោស

---

[3] សេចក្ដីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី៖ អំពីការដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីៗ ចំនួន ២ ចេញផ្សាយថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។ សេចក្ដីថ្លែងការណ៍សាធារណៈដោយសហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ចេញផ្សាយថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្ដីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងបន្ទុកការងាររបស់ អ.វ.ត.ក ចេញផ្សាយថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

ម្នាក់ៗឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលាដំបូង។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្ដឹងសាទុក្ខកម្រិត ត្រឹមតែស្នើសុំសេចក្ដីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុត នៃសហឧក្រិដ្ឋកម្ម រួមដែលហៅថា JCE III ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿងនេះត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយមានការប្រកាសសាលដីកាអង្គជំនុំជម្រះតុលាការកំពូល និងបិទផ្លូវតវ៉ា។ អង្គជំនុំជម្រះតុលាការកំពូលតម្កល់សាលក្រមសាលាដំបូងដែលផ្ដន្ទាទោសជនជាប់ចោទទាំងពីរដាក់ពន្ធនាគារអស់មួយជីវិត។

៦ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែលអង្គជំនុំជម្រះវិសាមញ្ញដាក់ឈ្មោះថាសំណុំរឿង ០០២/០២ គឺផ្ដោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។ បទចោទទាំងនោះរួមមាន៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រធានបទ ការប្រព្រឹត្តិលើជនជាតិចាម វៀតណាម សហករណ៍ត្រាំកក់ (រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់និងការប្រព្រឹត្តលើពុទ្ធសាសនិក) ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខអូរកន្សែង ភ្នំក្រោល និងស-២១ ការបោសសម្អាតផ្ទៃក្នុង និងការដាក់បទបញ្ជាលើអាពាហ៍ពិពាហ៍។ សវនាការលើភស្តុតាងចាប់ផ្ដើមនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ហើយបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការចំនួន២៧៤ថ្ងៃ និងស្ដាប់សក្ខីកម្មសាក្សីចំនួន ១១៤ នាក់ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៣ នាក់ និងអ្នកជំនាញចំនួន៨នាក់។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សំណើទាមទារសំណងចុងក្រោយរបស់ខ្លួននៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧។ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។ បច្ចុប្បន្ននេះ អង្គជំនុំជម្រះកំពុងពិភាក្សាសម្រេចអំពីសាលក្រមរបស់ខ្លួន និងធ្វើសេចក្ដីព្រាងសាលក្រមដោយមានសំអាងហេតុ ដែលសាលក្រមនេះរំពឹងថានឹងចេញនៅត្រឹមដំណាច់ត្រីមាសទីពីរឆ្នាំ ២០១៨។

៧ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្ដីសម្រេចបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ដែលមិនមាន

បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ដំណើរការនីតិវិធីតុលាការក្នុងសំណុំរឿង០០២ នឹងត្រូវបញ្ចប់នៅពេលសាលក្រមសំណុំរឿង០០២/០២ ចូលជាស្ថាពរ។

៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបន្តស៊ើបអង្កេតសំណុំរឿង០០៣ និង ០០៤ ពាក់ព័ន្ធនឹងការចោទប្រកាន់លើជនត្រូវចោទចំនួន៤នាក់។

ក- នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ចប់កិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ ជាលើកទីពីរ បន្ទាប់ពីការស៊ើបសួរបន្ថែម។ កិច្ចនានាត្រូវបានអនុវត្តតាមសំណើរបស់ភាគី។ ដីកាដំណោះស្រាយរំពឹងថានឹងចេញនៅត្រីមាសទី១ ឆ្នាំ២០១៨។

ខ- សហចៅក្រមស៊ើបអង្កេតកំពុងរៀបចំបញ្ចប់ឯកសារនានាដែលរួមមានសំអាងហេតុពេញលេញសម្រាប់ដីកាដំណោះស្រាយផ្នែកសម្រេចសេចក្តី នៅក្នុង*សំណុំរឿង ០០៤/០១* ដែលបានចេញនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧[4]។

គ- នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យនៅក្នុងសំណុំរឿង ០០៤/០២ ដោយស្នើសុំឱ្យសហព្រះរាជអាជ្ញា ដាក់សេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន។ នៅពេលនេះ សហព្រះរាជអាជ្ញាត្រូវដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួនក្នុងរយៈពេលបីខែ។ ដីកាដំណោះស្រាយក្នុងសំណុំរឿងនេះរំពឹងថានឹងចេញនៅត្រីមាសទី១ ឆ្នាំ ២០១៨។

ឃ- នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរនៅក្នុង*សំណុំរឿង ០០៤* ប្រឆាំងនឹង យឹម ទិត្យ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចដាច់ដោយឡែកមួយកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ នៅក្នុងថ្ងៃដដែលនោះដែរ។ ដីកាដំណោះស្រាយនៅក្នុងរឿងក្តីនេះ រំពឹងថានឹងចេញនៅក្នុងអំឡុងត្រីមាសទី១ ឆ្នាំ ២០១៨។

[4] ដីកាដំណោះស្រាយដែលមានសំអាងហេតុពេញលេញសម្រាប់ការលើកលែងការចោទប្រកាន់ បានចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧។

៩ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញ កំណត់ព្រឹត្តិការណ៍សំខាន់ចំនួន១១ សម្រាប់សំណុំរឿងដែលអង្គជំនុំជម្រះនានាបានទទួល។ ព្រឹត្តិការណ៍សំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២ និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺៈ

(i) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី២ ឆ្នាំ២០១៨)។

(ii) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទី៣ ឆ្នាំ២០១៨) និង

(iii) ការចេញសាលដីកានៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទី១ ឆ្នាំ២០២០)។

១០ នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង០០៤ សំណុំរឿង០០៤/០១ និងសំណុំរឿង០០៤/០២ ព្រឹត្តិការណ៍ដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបសួរ ដែលនៅសេសសល់ ហើយ ក្នុងករណីមានការចោទប្រកាន់នោះនឹងមានព្រឹត្តិការណ៍សំខាន់បន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និង បណ្តឹងសាទុក្ខ[5]។ ព្រឹត្តិការណ៍សំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលបន្តនៅសេសសល់ គឺៈ

(iv) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្តីសម្រេច ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០១៨)។

(v) សេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទី៣ ឆ្នាំ២០១៨) ។

(vi) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០១៨)។

[5] ដីកាដំណោះស្រាយ ក្រោយពីបញ្ចប់កិច្ចស៊ើបសួរ នឹងបញ្ជាក់ថានឹងមានការចោទប្រកាន់ឬទម្លាក់ការចោទប្រកាន់។ ដោយសារស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។

01739950

(vii) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៨)។

(viii) ការចេញដីកាដំណោះស្រាយដែលមានសំអាងហេតុពេញលេញ ក្នុងសំណុំរឿង០០៤/០១ (ត្រីមាសទី៣ ឆ្នាំ២០១៧)[6]។

(ix) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង០០៤/០១ ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៤ ឆ្នាំ២០១៧)[7]។

(x) ការចេញដីកាដំណោះស្រាយសំណុំរឿង០០៤/០២ ជាមួយនឹងសេចក្តីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី១ ឆ្នាំ២០១៨)។

(xi) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤/០២ថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទី៣ ឆ្នាំ២០១៨)។

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១១ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញកន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្តាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំសារពើពន្ធ២០១៤-២០១៧ សម្រាប់ភាគីអន្តរជាតិនៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកានិងធ្វើឲ្យមានការផ្តោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ ប៉ុន្តែ ចំពោះភាគីជាតិវិញ ការលំបាកផ្នែកលំហូរសាច់

[6] ឯកសារដែលរួមមានសំអាងហេតុពេញលេញសម្រាប់ដីកាដំណោះស្រាយ បានចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

[7] អង្គបុរេជំនុំជម្រះបានបញ្ជាក់កាលពីមុនថា ភាគីអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ក្រោយពីជូនដំណឹងអំពីសំអាងហេតុពេញលេញ។

ប្រាក់បាននាំឲ្យមានការពន្យារពេលបើកប្រាក់បៀវត្សសម្រាប់បុគ្គលិកជាតិនៅក្នុងកំឡុងពាក់កណ្ដាលឆ្នាំ២០១៥ ដែលប៉ះពាល់ដល់ការផ្ដោតអារម្មណ៍ និងទឹកចិត្តបំពេញការងារ។

១២ ក្រោយពីមានការសម្ដែងនូវការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ មហាសន្និបាតអង្គការសហប្រជាជាតិ ជាវិធានការពិសេស បានអនុញ្ញាតឲ្យអគ្គលេខាធិការសម្រេចកំណត់ទឹកប្រាក់ចំនួនមិនលើសពី ១១ លានដុល្លារ ដើម្បីបន្ថែមបង្គ្រប់ធនធានថវិកាស្ម័គចិត្តរបស់ភាគីអន្តរជាតិនៃ អ.វ.ត.ក សម្រាប់រយៈពេលគិតចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។ សកម្មភាពទាន់ពេលវេលានេះបានជួយសម្រួលយ៉ាងសំខាន់ ដល់ប្រតិបត្តិការកុំឲ្យរអាក់រអួលនៅអំឡុងឆមាសទី១ ឆ្នាំ២០១៧ ដោយបើកឱកាសឲ្យមានការរៃអង្គាសថវិកាស្ម័គ្រចិត្តបន្តទៀត។ ជាងនេះទៀត ការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្ដល់វិភាគទានដោយផ្ទាល់ម្ដងទៀតគិតត្រឹមឆ្នាំ២០១៦ ដើម្បីចំណាយទៅលើប្រាក់បៀវត្សបុគ្គលិកជាតិ៦ខែដំបូង ក៏ដូចជាចំណាយប្រតិបត្តិការសម្រាប់ឆ្នាំ២០១៧ គឺជាវិធានការដ៏សំខាន់ដែលជួយដល់ប្រតិបត្តិការបច្ចុប្បន្នរបស់ភាគីជាតិនៃអ.វ.ត.ក។ ដោយរួមបញ្ចូលគ្នាបែបនេះ វិធានការទាំងនេះធានាថា ដំណាក់កាលដែលមានទំហំការងារច្រើនបំផុតបច្ចុប្បន្ននៅក្នុងកិច្ចការរបស់ អ.វ.ត.ក បានបន្តទទួលបាននូវការយកចិត្តទុកដាក់ជានិច្ចឆ្ពោះទៅ៦ខែដំបូង នៃឆ្នាំ២០១៧។ លើសពីនេះទៀត វិភាគទានស្ម័គ្រចិត្តសម្រាប់ឆ្នាំ ២០១៧ នាពេលថ្មីៗនេះត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១០,៧លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ១,៧៥លានដុល្លារសម្រាប់ភាគីជាតិ។ ទោះបីជាកិច្ចខិតខំប្រឹងប្រែងរៃអង្គាសថវិកាកំពុងបន្តដំណើរការ ហើយមូលនិធិបន្ថែមអាចនឹងមានក្នុងពេលឆាប់ៗខាងមុខនេះក៏ដោយ ក៏មូលនិធិដែលបានប៉ាន់ស្មានទុក គ្រប់គ្រាន់សម្រាប់កិច្ចការតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងការបន្តដំណើរការពេញមួយឆ្នាំនេះដែរ។

ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោមត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋាន ថា អង្គជំនុំជម្រះ និងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថា កិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនឹងមិនត្រូវរំខានដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុលេចឡើងម្ដងទៀត យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១៣ នៅខែមករា ឆ្នាំ២០១៥ កិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក បានអនុម័តវិសោធនកម្មទៅលើវិធាន ផ្ទៃក្នុងដែលអនុញ្ញាតឲ្យមានការកាត់បន្ថយទៅលើវិសាលភាពកិច្ចស៊ើបសួរល្អិតណាវិសាលភាពស៊ើបអង្កេត

ដែលបានកាត់បន្ថយជាតំណាងឲ្យបទចោទ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ តាមការចោទប្រកាន់[8]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរពាក់ព័ន្ធនឹង មាស មុត ក្នុងសំណុំរឿង០០៣, អោ អាន ក្នុងសំណុំរឿង០០៤/០២ និង យឹម ទិត្យ ក្នុងសំណុំរឿង ០០៤ អនុលោមតាមបទបញ្ញត្តិនេះ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាច កាត់បន្ថយវិសាលភាព នៃការជំនុំជម្រះក្តីមួយដោយមិនរួមបញ្ចូលអង្គហេតុជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងដីកាបញ្ជូន រឿងទៅជំនុំជម្រះដរាបណាអង្គហេតុដែលនៅសល់ដែលត្រូវជម្រះ គឺជាតំណាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជម្រះ[9]។ ឈរលើមូលដ្ឋាននេះ អង្គជំនុំជម្រះសាលា ដំបូងបានបញ្ចប់កិច្ចនីតិវិធីពាក់ព័ន្ធនឹងអង្គហេតុដែលមានចែងក្នុងសំណុំរឿង០០២ ដែលមិនមានបញ្ចូល នៅក្នុង សំណុំរឿង០០២/០១ ឬ០០២/០២។ ហេតុដូច្នេះ ការសម្រេចសេចក្តីចុងក្រោយនៃសំណុំរឿង ០០២/០២ នឹងបញ្ចប់នូវកិច្ចនីតិវិធីសំណុំរឿង០០២ តែម្តង។

១៤ ក្នុងគោលបំណងបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌ បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ បានជំរុញឲ្យដំណាក់កាលស៊ើបសួរបានលឿន។ ជាងនេះទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលលទ្ធផលពីធនធានមនុស្សរបស់ខ្លួន ជាមួយនឹងបុគ្គលិកជំនាញក្រោមកម្ចីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដែលបង្កើនលទ្ធផលនៃកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្តទាក់ទងរដ្ឋជាសមាជិក និងអង្គការវិជ្ជាជីវៈនានាក្នុងគោលបំណងជ្រើសរើសបុគ្គលិកមិនយកប្រាក់កម្រៃបន្ថែមទៀត។ ជាងនេះទៀត ការិយាល័យរដ្ឋបាលបានរក្សាសេវាកម្មរបស់បុគ្គលិកឯកទេសភាសាបន្ថែមទៀត ដើម្បីគាំទ្រដល់ការិយាល័យតុលាការដើម្បីធានាសេវាបកប្រែនិងប្រតិចារឹកបានទាន់ពេលវេលា។

---

8 វិធាន៦៦ស្ទួន អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតដកចេញអង្គហេតុជាក់លាក់មួយចំនួនពីការស៊ើបអង្កេតដរាបណាអង្គហេតុដែលនៅសល់អាចយកមកធ្វើជាតំណាងចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ សេចក្តីសម្រេចប្រើវិធាន៦៦ស្ទួនគឺតម្រូវដោយច្បាប់ដែលនឹងធ្វើនៅដំណាក់កាលជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ។

9 វិធាន៨៩*ស្ទួន៣*។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៥ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ ត្រូវបានផ្តួចផ្តើមឡើងក្រោយពីមានដីកាបញ្ជូនរឿងឲ្យស៊ើបសួរដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅខែកញ្ញា ឆ្នាំ២០០៩ ហើយក្រោយពីដាក់ សេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយចំនួនទៀត សំណុំរឿង០០៤ក៏ត្រូវបំបែកទៅជាសំណុំរឿងចំនួន៣ ពោលគឺ៖ សំណុំរឿង០០៤/០១ ពាក់ព័ន្ធ អ៊ឹម ចែម សំណុំរឿង០០៤/០២ ពាក់ព័ន្ធ អោ អាន និង សំណុំរឿង០០៤ ប្រឆាំងនឹង យឹម ទិត្យ។ ដំណាក់កាលស៊ើបអង្កេតរួមមានយុត្តាធិការរបស់(ក) ការិយាល័យសហចៅក្រមស៊ើបអង្កេត និង (ខ) យុត្តាធិការរបស់អង្គបុរេជំនុំជម្រះនៅដំណាក់កាលបណ្តឹងសាទុក្ខ។

### ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត

១៦ ចាប់តាំងពីកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្តើមមក មានការចុះបំពេញបេសកកម្មជាក់ស្តែងចំនួន២៦៩លើក និងធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១៤១៣នាក់។ នៅក្នុងឆ្នាំ ២០១៧ បានបំពេញបេសកកម្មចំនួន ១៧លើក ដោយធ្វើកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន៥៧នាក់។ ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង២៥០០នាក់ ដែលបានដាក់ក្នុងសំណុំរឿងទាំងពីរបច្ចុប្បន្ន កំពុងស្ថិតក្រោមការពិនិត្យដើម្បីរៀបចំសេចក្តីសម្រេចទទួលស្គាល់ ឬបដិសេធ។

១៧ នៅចុងបញ្ចប់នៃរយៈពេលធ្វើរបាយការណ៍នេះ ស្ថានភាពសំណុំរឿងមានដូចខាងក្រោម៖

ក. ក្នុងសំណុំរឿង០០៤/០១ សហចៅក្រមស៊ើបអង្កេតកំពុងរៀបចំបញ្ចប់ឯកសារនានា ដែលរួមមានសំអាងហេតុសម្រាប់ដីកាដំណោះស្រាយដែលបានចេញនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧[10]។

ខ. ក្នុងសំណុំរឿង០០៤/០២ សហចៅក្រមស៊ើបអង្កេតទាំងពីររូប បានបញ្ជូនសំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញានៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ដើម្បីស្នើសុំឲ្យសហព្រះរាជអាជ្ញាចេញសេចក្តីសន្និដ្ឋានស្ថាពរ។

---

[10] ឯកសារនេះចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

គ. ក្នុងសំណុំរឿង០០៣ សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរជាលើកទីពីរនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ បន្ទាប់ពីបានបំពេញកិច្ចស៊ើបសួរបន្ថែមតាមសំណើរបស់ភាគីនានា។

ឃ. កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ ត្រូវបានបិទបញ្ចប់នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចមួយ អនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង នៅក្នុងថ្ងៃដដែលនោះ ដែលជាក់ស្តែងបានកាត់បន្ថយចំនួនពាក់កណ្តាលនៃទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ពីដំបូង។

១៨ ដោយសារតែនៅពេលនេះកិច្ចស៊ើបសួរទាំងអស់បានបិទបញ្ចប់ហើយនោះ កិច្ចការស៊ើបអង្កេត រំពឹងថានឹងមានការកាត់បន្ថយយ៉ាងច្រើន ផ្អែកលើវិសាលភាពនៃសំណើសុំបំពេញកិច្ចស៊ើបសួរដែលនៅសេសសល់នៅក្នុងសំណុំរឿង ០០៤។ កិច្ចការចម្បងនានានឹងបង្វែរទៅធ្វើការដោះស្រាយលើសំណើសំខាន់ៗពាក់ព័ន្ធនឹងនីតិវិធី និងរៀបចំសេចក្តីព្រាងដីកាដំណោះស្រាយសម្រាប់សំណុំរឿងទាំងអស់ដែលនៅបន្តដំណើរការនីតិវិធី នៅពេលមានការដាក់សេចក្តីសន្និដ្ឋានស្ថាពរ។

១៩ ដំណើរការទៅមុខ នៅតែអាស្រ័យលើកត្តានានាដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចៅក្រមឧទាហរណ៍ ដូចជា ថវិកាគ្រប់គ្រាន់ និងនីតិវិធីជ្រើសរើសបុគ្គលិកទាន់ពេលវេលាសម្រាប់តំណែងដែលទំនេរ ការបកប្រែឯកសារបានឆាប់រហ័ស ការបកប្រែផ្ទាល់មាត់បានគ្រប់គ្រាន់ និង សមត្ថភាពធ្វើប្រតិចារឹក។ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានពន្យារពេលបំពេញការងាររបស់អ្នកហាត់ការក្នុងចំនួនយ៉ាងច្រើន ជាមធ្យមគឺពី ១ ទៅ ២នាក់ ខាងភាគីជាតិ និងពី១១ ទៅ ១៣នាក់ខាងភាគីអន្តរជាតិ ក្នុង ពេលនីមួយៗ។ បុគ្គលិកស្ទើរតែទាំងអស់មានតួនាទីច្រើននៅក្នុងក្រុមនានា ឬមានតួនាទីរដ្ឋបាល ទោះជាតួនាទីនោះអចិន្ត្រៃយ៍ក្តី ឬមិនអចិន្ត្រៃយ៍ក្តី។

២០ ចំនួនបុគ្គលិកមានកម្រិត និងសមាសភាពរបស់បុគ្គលិក ធ្វើឲ្យការិយាល័យចៅក្រមស៊ើបអង្កេតងាយប្រឈមនឹងកង្វះបុគ្គលិក ទោះបីជាក្នុងករណីមានបុគ្គលិកមួយចំនួនតូចឈប់ពីការងារក៏ដោយ ដែលជាហានិភ័យធ្ងន់ធ្ងរចំពោះកិច្ចការធានាការចងចាំការងារស្ថាប័ន ក៏ដូចជាលទ្ធភាពក្នុងការស្រូបយកទំហំ

ការងារពីការដាក់ឯកសាររបស់ភាគី និង សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ នៅពេលនេះ សំណើនានាពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារពីអង្គជំនុំជម្រះសាលាដំបូង បានបញ្ចប់ហើយ[11]។

២១ សំណើសុំបំពេញកិច្ចស៊ើបសួររបស់ភាគី អាចបណ្តាលឱ្យមានកិច្ចប្រឹងប្រែងដ៏ធំ។ ការបដិសេធនូវសំណើបែបនេះអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ ពេលវេលានិងលទ្ធផលនៃសេចក្តីសម្រេចទាំងនេះអាចជះឥទ្ធិពលទៅលើទម្រង់ និង រយៈពេលនៃកិច្ចស៊ើបអង្កេត។ ករណីដូចគ្នានេះដែរ គឺសំណើសុំមោឃភាព ដែលបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ។ កត្តាទាំងនេះពិតជាមានផលប៉ះពាល់ធ្ងន់ធ្ងរដល់តារាងកំណត់ពេលវេលា។ ដោយហេតុថាដីកាដំណោះស្រាយ ដោះស្រាយនូវកំហុសនីតិវិធីទាំងអស់នៅក្នុងកិច្ចស៊ើបសួរ ភាគីត្រូវតែលើកឡើងនូវបញ្ហាពាក់ព័ន្ធណាមួយមុនឈានដល់ដំណាក់កាលនោះ ឬបើមិនដូច្នេះទេនឹងប្រថុយនឹងការមិនបញ្ចូលនូវទឡ្ហីករណ៍ណាមួយ ដែលមិនបានលើកឡើងនៅពេលសវនាការ។ ដោយអាស្រ័យលើភាពស្មុគស្មាញនៃសំណើ គឺអាចត្រូវការពេលចំនួន៣ខែ ឬច្រើនជាងនេះ ចាប់ពីពេលដាក់សំណើរហូតដល់ពេលចេញសេចក្តីព្រាងសេចក្តីសម្រេចលើកទី១របស់សហចៅក្រមស៊ើបអង្កេត។

២២ នៅពេលកិច្ចស៊ើបសួរបានបិទបញ្ចប់ ភាគីទាំងអស់ទទួលបានការជូនដំណឹង ហើយអាចស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម។ ប្រសិនបើសំណើមួយត្រូវបានបដិសេធ ភាគីអាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ក្នុងរយៈពេល៣០ថ្ងៃ។ ទាល់តែរយៈពេលនោះចប់ លះបង់ ឬបណ្តឹងឧទ្ធរណ៍ទាំងនោះត្រូវបានបើកសវនាការ ទើបសំណុំរឿងនោះបញ្ជូនទៅសហព្រះរាជអាជ្ញាសម្រាប់ធ្វើដីកាសន្និដ្ឋានស្ថាពរ។ ដោយហេតុថាពុំមានជនត្រូវចោទណាម្នាក់ស្ថិតក្នុងការឃុំខ្លួននៅឡើយ ពេលវេលាសម្រាប់ដាក់ដីកាសន្និដ្ឋាន គឺមានរយៈពេល៣ខែ។ មេធាវីការពារក្តីទទួលបានពេលវេលាគ្រប់គ្រាន់សម្រាប់ឆ្លើយតប។

២៣ បន្ទាប់ពីនេះ សហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីព្រាងដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនទៅជំនុំជម្រះពេញលេញ ឬដោយផ្នែក ឬដីកាលើកលែងការចោទប្រកាន់[12]។ ពេលវេលា សម្រាប់ធ្វើ

---

[11] កិច្ចការបន្ថែមត្រូវបានបំពេញ ពាក់ព័ន្ធនឹងសំណើមួយដែលដាក់ដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៧ ដើម្បីដកសំណៅកោសលុប និងប្រើរហសនាមក្នុងសំណុំ រឿង០០២/០២។ ការណ៍នេះទាក់ទិននឹងការពិនិត្យឯកសារចំនួនរាប់រយដែលដាក់បង្ហាញទៅក្នុងសំណុំរឿង០០២/០២ ពីការស៊ើបអង្កេតនៃសំណុំរឿង០០៣ និង០០៤។

សេចក្តីព្រាងគឺប្រហែល៣ខែ សម្រាប់សំណុំរឿង០០១ ដ៏តូច និងប្រហែល៨ខែ សម្រាប់ សំណុំរឿង០០២ ដែលមានភាពស្មុគស្មាញស្រដៀងគ្នានឹងសំណុំរឿង ០០៤។ ការផ្តល់សេវាបកប្រែទាន់ពេលវេលា និងវត្តមានបន្តរបស់បុគ្គលិកច្បាប់ដែលមានបទពិសោធន៍នឹងមានឥទ្ធិពលយ៉ាងខ្លាំង នៅក្នុងអំឡុងដំណាក់កាលធ្វើសេចក្តីព្រាង។ ការចាកចេញរបស់បុគ្គលិកសំខាន់ៗ ស្ថានភាពថវិកាទូទៅ ការខិតជិតមកដល់នៃ អាណត្តិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬការរៀបចំផែនការអាជីព បង្ហាញហានិភ័យធ្ងន់ធ្ងរមួយទៀតសម្រាប់ពេលវេលាដែលបានគ្រោងទុក[13]។

២៤ មានសំណើ ញត្តិស្នើសុំមោឃភាព ឬសេចក្តីជូនដំណឹងបណ្តឹងឧទ្ធរណ៍ចំនួន១៥ ពាក់ព័ន្ធសំណុំរឿងទាំងអស់ត្រូវបានដាក់ជូនសហចៅក្រមស៊ើបអង្កេត ហើយបច្ចុប្បន្នកំពុងរង់ចាំសេចក្តីសម្រេចពោលគឺ៖ សំណើចំនួន៤ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ចំនួន៦ និង ញត្តិស្នើសុំមោឃភាពចំនួន៥[14]។ ឯកសារចំនួន ៩ ក្នុងចំណោមឯកសារទាំងនោះ ត្រូវបានដាក់ជូន បន្ទាប់ពីកំណែចុងក្រោយនៃគម្រោងបញ្ចប់ផែនការនេះ។

២៥ កត្តាទាំងនេះ ទំនងជាជះឥទ្ធិពលថ្មីមួយទៀតទៅលើរឿងក្តីនីមួយៗ ជាពិសេស ការដាក់បន្ថែមសំណើ ញត្តិ និងសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ចាប់តាំងពីមានកំណែចុងក្រោយមក និងភាពមិនប្រាកដប្រជា ទាក់ទិននឹង ចំនួន និងភាពស្មុគស្មាញនៃសំណើ ញត្តិ និងសេចក្តីជូនដំណឹងអំពីបណ្តឹង

---

[12] ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនអាចកំណត់ផលប៉ះពាល់ទៅលើពេលវេលាដែលបានគ្រោងទុកនេះក៏ដោយ ក៏ក្រៅពីការព្រមានឲ្យដឹងជាមុនយ៉ាងច្រើននោះ សហចៅក្រមស៊ើបអង្កេតមានចេតនាចង្អុលបង្ហាញអំពីសក្តានុពលដែលត្រូវការពេលវេលាបន្ថែមទៀត នៅក្នុងករណីជាសម្មតិកម្មដែលថាសហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា បន្ទាប់ពីមានការខ្វែងយោបល់គ្នានោះ។

[13] នៅត្រឹមពាក់កណ្តាលខែ សីហា មន្ត្រីច្បាប់ពីររូបនៅក្នុងក្រុមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនឹងត្រូវឈប់ពីការងារ។ ពួកគាត់កំពុងបំពេញការងារនៅក្នុងសំណុំរឿង ០០៣ ហើយការចាកចេញរបស់ពួកគាត់នឹងមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើវឌ្ឍនភាពនៃសំណុំរឿងពាក់ព័ន្ធទៅដល់ការចេញដីកាដំណោះស្រាយ ដែលកម្រិតនៃផលប៉ះពាល់នេះ គឺអាស្រ័យជាចម្បងទៅលើល្បឿន និងគុណភាពរបស់អ្នកដែលអាចមកជំនួសមន្ត្រីច្បាប់ទាំងពីររូបនេះ។

[14] ស្ថិតិរបស់សហចៅក្រមស៊ើបអង្កេតមានសុក្រឹត្យភាពគិតត្រឹមថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។ ចំនួនអាចមានការប្រែប្រួលនៅត្រឹមពេលចេញផ្សាយគម្រោងបញ្ចប់ផែនការនេះ។ តាមវិធាន៧៥(២)និង៧៦(៣) ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវចុះបញ្ជីការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងញត្តិស្នើសុំមោឃភាពទាំងអស់ ពីព្រោះការជូនដំណឹង និង ញត្តិទាំងនេះត្រូវបានដាក់ជូនសហចៅក្រមស៊ើបអង្កេត។

01739957

ឧទ្ធរណ៍នាពេលខាងមុខ និងការលាឈប់ពីការងាររបស់បុគ្គលិកនៅក្នុងសំណុំរឿង ០០៣។ វាជាការឆាប់រហ័សពេកក្នុងការកំណត់ចំនួនជាក់លាក់អំពីការពន្យារពេលនោះ ដូច្នេះហើយតារាងពេលវេលាសម្រាប់ពេលបច្ចុប្បន្ននេះគឺនៅដដែល ដូចនៅក្នុងកំណែចុងក្រោយនៃគម្រោងបញ្ចប់ផែនការនេះ។ ទោះបីយ៉ាងណាក៏ដោយ មានការសង្កត់ធ្ងន់ថា ភវនីយភាពនៃការពន្យារពេលបន្ថែមយ៉ាងហោចណាស់បីខែទៀត ជាពិសេសក្នុងសំណុំរឿង ០០៣ និង ០០៤ មានកម្រិតខ្ពស់មែនទែន។ តារាងពេលវេលានេះគួរត្រូវបានចាត់ទុកត្រឹមតែជាការប៉ាន់ប្រមាណបណ្ដោះអាសន្នប៉ុណ្ណោះ។

ក. ក្នុងសំណុំរឿង០០៣ ដីកាដំណោះស្រាយ គ្រោងនឹងចេញនៅត្រឹមត្រីមាសទី១ ឆ្នាំ២០១៨។

ខ. ក្នុងសំណុំរឿង០០៤ ដីកាដំណោះស្រាយ គ្រោងនឹងចេញនៅត្រីមាសទី១ ឆ្នាំ ២០១៨។

គ. ក្នុងសំណុំរឿង០០៤/០១ សហចៅក្រមស៊ើបអង្កេតបច្ចុប្បន្នកំពុងរៀបចំបញ្ចប់ សំអាងហេតុសម្រាប់ដីកាដំណោះស្រាយ ដែលនឹងប្រកាសនៅត្រីមាសទី៣ ឆ្នាំ២០១៧[15]។

ឃ. ក្នុងសំណុំរឿង០០៤/០២ ដីកាដំណោះស្រាយគ្រោងនឹងចេញនៅត្រីមាសទី១ ឆ្នាំ២០១៨។

## ខ. <u>អង្គបុរេជំនុំជម្រះ</u>

២៦ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចជាស្ថាពរលើបញ្ហាទាំងអស់ចំនួន៦ ដែលរង់ចាំការសម្រេចនៅដើមត្រីមាសនេះ។ ខណៈដែលពុំមានការកំណត់ពេលវេលាតាមច្បាប់សម្រាប់អង្គបុរេជំនុំជម្រះចេញសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ អង្គជំនុំជម្រះបានរៀបចំដំណើរការរបស់ខ្លួនឲ្យបានលឿន និងមានប្រសិទ្ធភាពក្នុងការចេញសេចក្ដីសម្រេចទាំងនេះក្នុងរយៈពេល៣ខែ គិតជាមធ្យម។សេចក្ដីសម្រេចចំនួន៥ ក្នុងចំណោមសេចក្ដីសម្រេចទាំងនេះ ត្រូវបានចេញក្នុងរយៈពេលពី ១ខែ ទៅ ៣ខែ។ អង្គបុរេជំនុំជម្រះនៅតែមានគោលបំណងកាត់បន្ថយពេលវេលាក្នុងការចេញសេចក្ដីសម្រេចលើបញ្ហានីមួយៗ។

២៧ នៅចុងបញ្ចប់នៃរយៈពេលធ្វើសេចក្ដីរាយការណ៍នេះ អង្គបុរេជំនុំជម្រះទទួលបណ្ដឹងឧទ្ធរណ៍ និងញត្តិស្នើសុំមោឃភាពចំនួន៧ ដែលសូមរៀបរាប់ដូចតទៅ[16]៖

---

[15] ដីកាដំណោះស្រាយដែលមានសំអាងហេតុពេញលេញបានចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០១៧។

01739958

ក. ក្នុងសំណុំរឿង០០៣ មានបណ្តឹងឧទ្ធរណ៍មួយ។

ខ. ក្នុងសំណុំរឿង០០៤/០២ បណ្តឹងឧទ្ធរណ៍ចំនួន២។

គ. ក្នុងសំណុំរឿង០០៤ ញត្តិស្នើសុំមោឃភាពចំនួន២។

២៨ ក្នុងសំណុំរឿង០០៤/០១ អង្គបុរេជំនុំជម្រះបានបញ្ជាក់ជូនភាគីនៅខែកុម្ភៈថា ភាគីអាចអនុវត្តសិទ្ធិប្តឹងឧទ្ធរណ៍ក្រោយពេល សំអាងហេតុពេញលេញសម្រាប់ដីកាដំណោះស្រាយត្រូវបានជូនដំណឹង តាមកំណត់ច្បាប់[17]។

២៩ អង្គជំនុំជម្រះរក្សាការតាំងចិត្តក្នុងការចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងពេលវេលាសមស្រប ដែលគ្រោងនឹងបញ្ចប់ក្នុងរយៈពេល៦ខែ អាស្រ័យលើលក្ខណៈនៃសេចក្តីសន្និដ្ឋាន និងបុគ្គលិកដែលមាន[18]។

## IV. ផែនការបញ្ចប់សវនាការ

៣០ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ ភាពទំនេរនិងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត ក្នុងនោះរួមមានការបកប្រែផ្ទាល់មាត់បានត្រឹមត្រូវ និងការបកប្រែឯកសារទាន់ពេលវេលា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

---

[16] មានរួមបញ្ចូលនៅក្នុងបញ្ជីសំណើ ញត្តិស្នើសុំមោឃភាព និងការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ដែលយោងនៅក្នុងកថាខណ្ឌ ២៤។

[17] ភាគីទទួលបានការជូនដំណឹងអំពីដីកាដំណោះស្រាយដែលមានសំអាងហេតុពេញលេញ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

[18] ក្នុងករណីដែលមានការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទៅលើពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ អង្គជំនុំជម្រះក៏នឹងត្រូវការពេលវេលាជាមធ្យមប្រហែលបីខែផងដែរ ដើម្បីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ទាំងអស់នោះ នៅពេលមានការចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

៣១ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្តើមសវនាការជាក់ស្តែង។ សវនាការចាប់ផ្តើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខានុពល និងអ្នកជំនាញ ដែលដាក់ជូនដោយភាគីព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តួចផ្តើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្តីចាប់ផ្តើមដោយមានការធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្តើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងស្តាប់នូវការបង្ហាញភស្តុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភស្តុតាងទាំងអស់រួចហើយអង្គជំនុំជម្រះស្តាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាសម្រេច។ ប្រសិនបើជនជាប់ចោទត្រូវផ្តន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្រប នៅក្នុងសាលក្រមនោះ។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវព្រឹត្តិការណ៍សំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

## ក. <u>សំណុំរឿង០០២/០២</u>

៣២ កិច្ចដំណើរការនីតិវិធីលើភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួន៣ថ្ងៃក្នុងមួយសប្តាហ៍។ លទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្ររបស់ជនជាប់ចោទនៅខែមករា ឆ្នាំ២០១៥បង្ហាញថា ការកំណត់៤ថ្ងៃក្នុង១សប្តាហ៍ជាការសមស្រប ដោយសវនាការពេលព្រឹកធ្វើឲ្យបានខ្លីបន្តិច។ ដូច្នេះអង្គជំនុំជម្រះបានត្រឡប់ទៅអនុវត្តតាមពេលកំណត់៤ថ្ងៃក្នុង១សប្តាហ៍វិញ នៅខែកុម្ភៈ ឆ្នាំ២០១៥ ដែលជាការពន្លឿនដល់ការជំនុំជម្រះក្តី។ សវនាការលើភស្តុតាងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ក្រោយពីពេលសវនាការអស់ចំនួន២៧៤ថ្ងៃ។ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មសាក្សីសរុបចំនួន១១៤ ដើមបណ្តឹង រដ្ឋប្បវេណីសរុបចំនួន ៦៣ និង អ្នកជំនាញចំនួន៨នាក់ នៅលើប្រធានបទសហករណ៍ត្រាំកក់ (ក្នុងនោះរួមមាន មន្ទីរសន្តិសុខក្រាំងតាចាន់ និងការប្រព្រឹត្តិលើជនជាតិចាម) ការដ្ឋានទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋាន

ទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តិលើជនជាតិចាម និងជនជាតិវៀតណាម មន្ទីរសន្តិសុខអូរកន្សែង និង ភ្នំក្រោល និងមន្ទីរសន្តិសុខស២១ ព្រមទាំងការបោសសម្អាតផ្ទៃក្នុង។ បទបញ្ជាឲ្យរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និង តួនាទីរបស់ជនជាប់ចោទ។

៣៣ ដើម្បីរៀបចំការបិទដំណើរការនីតិវិធី អង្គជំនុំជម្រះបានធ្វើកិច្ចប្រជុំរៀបចំសវនាការនៅខែធ្នូ ឆ្នាំ២០១៦ ដើម្បី ស្តាប់សារណាពាក់ព័ន្ធនឹងសារណាបញ្ចប់ការដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់ការដេញ ដោលក្នុងចំណោមបញ្ហាដទៃៗទៀត។ដោយកត់សម្គាល់បញ្ហាចម្បងៗលើកឡើងដោយភាគី ជាពិសេស រយៈពេលវែងខុសពីធម្មតា និងភាពស្មុគស្មាញនៃរឿងក្តី អង្គជំនុំជម្រះក៏កំណត់កាលបរិច្ឆេទសម្រាប់ដាក់ សារណាសវនាការនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងការចាប់ផ្តើមសេចក្តីសន្និដ្ឋានបញ្ចប់ការ ពិភាក្សាដេញដោលនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧។ ក្រោយមក អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគី មានពេលវេលាបន្ថែមមួយសប្តាហ៍ទៀត ដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយសារ តែការពិនិត្យឡើងវិញលើប្រតិចារឹកសវនាការរបស់អង្គភាពប្រតិចារឹកកំពុងបន្តដំណើរការ ដែល ប្រការនេះបានបង្កជាផលវិបាកដល់ភាគីក្នុងការពឹងផ្អែកទៅលើកំណត់ហេតុរបស់តុលាការ នៅក្នុង សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហេតុនេះ ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញ ដោល ត្រូវបានកំណត់ពេលឡើងវិញ និងបានធ្វើឡើងចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧។ បន្ទាប់ពីនោះមក អង្គជំនុំជម្រះបានផ្អាកសវនាការដើម្បីពិភាក្សាសម្រេច និងរៀបចំសាល ក្រមនៅក្នុងរឿងក្តីនេះ។

៣៤ ការប៉ាន់ស្មានដំបូងទៅលើតម្រូវការពេលវេលាក្នុងការចេញសាលក្រមក្នុងសំណុំរឿង០០២/០២ គឺធ្វើ ឡើងមុនពេលចាប់ផ្តើមការជំនុំជម្រះដោយផ្អែកលើបទពិសោធន៍សំណុំរឿង០០២/០១ ដោយពុំទាន់ បានដឹងមានសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ចំនួនប៉ុន្មាននាក់នឹងត្រូវផ្តល់សក្ខីកម្ម។ ការប៉ាន់ស្មាននេះ ត្រូវបានកែសម្រួលឡើងវិញនៅក្នុងសំណៅគម្រោងបញ្ចប់ផែនការលើកមុន ដោយ ចារណាទៅលើការណ៍ដែលថាមានសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ក្នុងចំនួនទ្វេដង ត្រូវបានស្តាប់សក្ខីកម្មនៅក្នុង សំណុំរឿង ០០២/០២ លើសសំណុំរឿង០០២/០១ ដែរ ដែលជា ការបង្កើតនូវមូលដ្ឋានភស្តុតាងធំជាងមុនច្រើន សម្រាប់ការពិចារណា និងវិភាគនៅក្នុងពេលពិភាក្សា សម្រេច និងដំណើរការព្រាងសាលក្រម។

៣៥ សមត្ថភាពរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំពេញទៅតាមតារាងពេលវេលាបច្ចុប្បន្ននេះ ដើម្បីចេញសាលក្រមនៅក្នុងរឿងក្តីនេះ នឹងអាស្រ័យជាបឋមទៅលើអង្គជំនុំជម្រះ និងអង្គភាពគាំទ្រដទៃទៀតដែលនៅមានបុគ្គលិកពេញលេញ។ នៅក្នុងអំឡុងឆ្នាំ ២០១៦ និងចូលមកដល់ត្រីមាសទី១ ឆ្នាំ ២០១៧ ការរៀបចំព្រាងសាលក្រមទទួលផលប៉ះពាល់ដោយការខ្វះបុគ្គលិកនៅក្នុងអង្គជំនុំជម្រះ។ ការលាឈប់ពីការងាររបស់បុគ្គលិកអាចរំពឹងថានឹងបន្តកើតមានទៀតនៅក្នុងអំឡុងឆ្នាំ ២០១៧ ដោយហេតុថាស្ថានភាពហិរញ្ញវត្ថុរបស់សាលាក្តីប្រែប្រួលមិនទៀងទាត់ ដែលជំរុញឱ្យបុគ្គលិកសម្លឹងរកការងារយូរអង្វែងកាន់តែច្រើនឡើងៗ។

៣៦ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ប្រាប់ការិយាល័យរដ្ឋបាលពីមុនមកអំពីបញ្ហាពាក់ព័ន្ធនឹងការបញ្ចប់ការបកប្រែឱ្យបានទាន់ពេលវេលា ដែលអាចពន្យារពេលបន្តទៀតក្នុងការចេញសាលក្រម។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្នុងខែធ្នូ ឆ្នាំ២០១៦ មេធាវីការពារក្តីបានលើកឡើងកត្តា ២ ថែមទៀត ដែលនឹងជះឥទ្ធិពលលើរយៈពេលនៃការរៀបចំសាលក្រម ពោលគឺ ការពិនិត្យប្រតិចារឹកដែលកំពុងតែធ្វើ និងការបកប្រែសាលដីកាអង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង០០២/០១ ទៅជាភាសាបារាំង។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ប្រតិចារឹកសវនាការដែលត្រឹមត្រូវ គឺជាមូលដ្ឋានសំខាន់សម្រាប់ការរៀបចំសាលក្រម ក៏ដូចជាការរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីនានាដែរ។ មេធាវីការពារក្តី នួន ជា បានស្នើឱ្យបញ្ចប់ការពិនិត្យប្រតិចារឹកមុនថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ដើម្បីឱ្យសារណាបញ្ចប់ការពិភាក្សាដេញដោលអាចឆ្លុះបញ្ចាំងពីព័ត៌មានត្រឹមត្រូវ។ យ៉ាងណាក៏ដោយ ការិយាល័យរដ្ឋបាលបានជូនដំណឹងទៅអង្គជំនុំជម្រះថា ដំណើរការពិនិត្យប្រតិចារឹកដែលអ្នកស្នើបានកំណត់ថាជាអាទិភាព នឹងត្រូវបញ្ចប់ត្រឹមដំណាច់ខែមេសា ហើយប្រតិចារឹកផ្សេងទៀតនឹងត្រូវបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៧។

៣៧ ដោយផ្អែកលើតារាងពេលវេលានេះ កាលពីខែ មេសា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាបានស្នើសុំពន្យារពេលចំនួន ១៥ថ្ងៃ ដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងកាត់បន្ថយរយៈពេលនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ដើម្បីបញ្ចប់សវនាការតាមការគ្រោងទុកពីមុន។ សំណើនេះ ភាគច្រើនត្រូវបានមេធាវីការពារក្តី ខៀវ សំផន យល់ស្រប។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំពន្យារពេលច្រើនជាងនេះទៀត ដោយស្នើឡើងថា កាលបរិច្ឆេទដាក់

សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល គួរត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៧ ហើយថា សវនាការអំពីសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល គួរត្រូវបានធ្វើឡើងនៅពេលណាមួយបន្ទាប់ពីកាលបរិច្ឆេទនេះ ដោយសំអាងទៅលើព័ត៌មានដែលថា ការកែតម្រូវប្រតិចារឹកទាំងអស់ដែលរួមមានសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរនោះ នឹងត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧។ មេធាវីការពារក្តី នួន ជា បានស្នើសុំថា កាលបរិច្ឆេទដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងកាលបរិច្ឆេទសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល គួរត្រូវបានរក្សាដដែល ប៉ុន្តែស្នើសុំឲ្យភាគីមានឱកាសដាក់ការកែតម្រូវទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន នៅពេលមានការពិនិត្យចប់សព្វគ្រប់ទៅលើប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី។

៣៨ អង្គជំនុំជម្រះបានសម្រេចថា ការពន្យារពេល ១ សប្តាហ៍ សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល គឺជាការសមស្រប ដោយអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧ និងបានកំណត់កាលបរិច្ឆេទធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលឡើងវិញ ដែលចាប់ផ្តើមនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧។ អង្គជំនុំជម្រះក៏បានយល់ស្របផងដែរតាមសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំដាក់ការកែតម្រូវទៅលើសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគី បន្ទាប់ពីការពិនិត្យបញ្ចប់ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី ដែលរំពឹងថានឹងបញ្ចប់នៅត្រឹមថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៧។ ពេលវេលាដែលចំណាយក្នុងការពិនិត្យបញ្ចប់ប្រតិចារឹកសវនាការនោះ បានធ្វើឲ្យមានភាពស្មុគស្មាញដល់ដំណើរការធ្វើសេចក្តីព្រាងសាលក្រម ដោយបង្កើតឲ្យមានភាពមិនច្បាស់លាស់ចំពោះសុក្រឹតភាពនៃកំណត់ហេតុសវនាការបច្ចុប្បន្ននេះ។ ប្រសិនបើភាគីកែប្រែច្រើនទៅលើទឡ្ហីករណ៍នានានៅក្នុងសារណាដែលបានកែតម្រូវរបស់ខ្លួន ដោយផ្អែកទៅលើការកែតម្រូវច្រើនទៅលើប្រតិចារឹកនោះ ប្រការនេះនឹងបន្ថែមនូវជំហានមួយទៀតចំពោះការវាយតម្លៃរបស់អង្គជំនុំជម្រះទៅលើភស្តុតាង។ នៅពេលនេះ អង្គជំនុំជម្រះមិនអាចកំណត់បានឡើយថាតើ វាអាចមានផលប៉ះពាល់អ្វីខ្លះទៅលើពេលវេលានៃការចេញសាលក្រមសំណុំរឿង ០០២/០២ នោះ។ នៅត្រីមាសទី៤ ឆ្នាំ ២០១៧ នេះ នឹងដឹងច្បាស់ជាងនេះ។

៣៩ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា នៅក្នុងអំឡុងពេលសវនាការស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល មេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា ការបកប្រែសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួនទៅជាភាសាខ្មែរឲ្យបានពេញលេញមុនការចេញសាលក្រម គឺជាបញ្ហាសក្តានុពលនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅក្នុងរឿងក្តីនេះ។ ប្រការនេះ បង្ហាញអំពីសារៈសំខាន់ក្នុងការរក្សាទុកបុគ្គលិកឲ្យបានគ្រប់គ្រាន់សម្រាប់កិច្ចការបកប្រែជូនអង្គជំនុំជម្រះ ដើម្បីអនុលោមទៅតាមកាលបរិច្ឆេទដែលបានកំណត់។

៤០ អង្គជំនុំជម្រះសាលាដំបូងបន្តពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប្រចាំ។ សម្បទារបស់ជនជាប់ចោទក្នុងការបន្តចូលរួមសវនាការត្រូវបានវាយតម្លៃនៅចុងខែកក្កដាឆ្នាំ២០១៦ ហើយពិនិត្យឃើញថាជន ជាប់ចោទទាំងពីរមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ប៉ុន្តែ របាយការណ៍វេជ្ជសាស្ត្រកត់សម្គាល់អំពីជំងឺមួយចំនួនដែលជនជាប់ចោទមាន ហើយបានផ្តល់អនុសាសន៍ឲ្យវាយតម្លៃទៅមុខងារសតិបញ្ញារបស់ជនជាប់ចោទរៀងរាល់ត្រីមាស។

៤១ ដោយពិចារណាទៅលើកត្តាទាំងឡាយខាងលើនេះ អង្គជំនុំជម្រះសូមរក្សាការប៉ាន់ស្មានពេលវេលានាពេលបច្ចុប្បន្នរបស់ខ្លួនក្នុងការចេញសាលក្រម នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១៨។

## ខ. <u>សំណុំរឿង០០៣ និង សំណុំរឿង០០៤</u>

៤២ លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ បើមិនដូច្នោះទេ យើងមិនអាចស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបានឡើយ។ ការវាយតម្លៃលើពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

## ក. <u>សំណុំរឿង០០២/០២</u>

៤៣ អង្គជំនុំជម្រះតុលាការកំពូលព្យាករណ៍នៅពេលនេះថា បណ្តឹងសាទុក្ខ (មួយឬច្រើន) ប្រសិនបើដាក់ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ នឹងមានចំនួនតិចបំផុត

01739964

ដោយសារពេលវេលានិងធនធាន ដូចក្នុងសំណុំរឿង០០២/០១ ដែរ។ រហូតទាល់តែចេញសាលក្រម ក្នុងសំណុំរឿង០០២/០២ ទើបមានលទ្ធភាពសម្រាប់ភាគីដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿងនោះ ដែលត្រូវតែសម្រេចនៅក្នុង រយៈពេលបីខែ កំណត់ដោយច្បាប់ ពន្យារពេលបួនខែ ក្នុងករណីពិសេស។

## ខ. <u>សំណុំរឿង០០៣/០០៤</u>

៤៤ ប្រសិនបើសំណុំរឿង០០៣ និង/ឬ ០០៤ បន្តទៅមុខរហូតដល់ដំណាក់កាលជំនុំជម្រះនោះ បណ្តឹងឧទ្ធរណ៍ភ្លាមៗឬបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទំនងជាកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាយើងមិនដឹងថាសំណុំរឿងណាមួយដំណើរការរហូតដល់ដំណាក់កាលជំនុំជម្រះ និងមិនដឹងពីបទចោទណាខ្លះនោះ វាហាក់ដូចជាឆាប់ពេកក្នុងការផ្តល់នូវការប៉ាន់ស្មានចំពោះពេលវេលាដែលតម្រូវក្នុងការសម្រេចលើបណ្តឹងសាទុក្ខណានៃសំណុំរឿងពាក់ព័ន្ធ។

## VI. សេចក្តីសន្និដ្ឋាន

៤៥ នៅក្នុងអំឡុងត្រីមាសទី២ ក្នុងឆ្នាំ២០១៧ ព្រឹត្តិការណ៍សំខាន់ៗចំនួនពីរត្រូវបានសម្រេចឡើង គឺ (i) ការបញ្ចប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ និង (ii) ការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ ប្រឆាំងនឹង យឹម ទិត្យ។

៤៦ ក្នុងរយៈពេលបន្តក្នុងឆ្នាំ ២០១៧ នេះ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួនពីរក្នុងសំណុំរឿង ០០៤/០១ ប្រឆាំង អ៊ឹម ចែម គឺ (i) ការចេញដីកាដំណោះស្រាយ ដែលមានសំអាងហេតុពេញលេញ[19] និង (ii) ការសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ដែលអាចមានប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងការបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៤៧ ក្នុងឆ្នាំ២០១៨ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់ៗចំនួនពីរក្នុងសំណុំរឿង០០២/០២ គឺ (i) ការចេញសាលក្រម និង (ii) ពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ដែលអាចមានប្រឆាំងនឹងសាលក្រម។ ចំពោះសំណុំរឿង ០០៣, ០០៤/០២ និង ០០៤ យើងរំពឹងថានឹងសម្រេចបាន

---

[19] ឯកសារដែលរួមមានសំអាងហេតុពេញលេញសម្រាប់ដីកាដំណោះស្រាយ បានចេញនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

ព្រឹត្តិការណ៍សំខាន់ៗចំនួនប្រាំមួយ គឺ (i) ការចេញដីកាដំណោះស្រាយសម្រាប់សំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី, (ii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី, (iii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ ដែលសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី និងការសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងឧទ្ធរណ៍ដែលអាចមាន ប្រឆាំងទៅនឹងដីកាដំណោះស្រាយទាំងនោះ ក្នុង (iv) សំណុំរឿង ០០៣ ពាក់ព័ន្ធនឹង មាស មុត (v) សំណុំរឿង ០០៤/០២ ពាក់ព័ន្ធនឹង អោ អាន និង (vi) សំណុំរឿង ០០៤ ពាក់ព័ន្ធនឹង យឹម ទិត្យ ក្នុងការបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៤៨ នៅឆ្នាំ ២០២០ យើងរំពឹងថានឹងសម្រេចបានព្រឹត្តិការណ៍សំខាន់មួយ គឺ (i) ការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២។

៤៩ ក្នុងករណីដែលសំណុំរឿង០០៣ និង សំណុំរឿង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទាំងមូល ឬដោយផ្នែក ពេលវេលាកំណត់សម្រាប់សំណុំរឿងទាំងនេះ នឹងត្រូវព្យាករឡើង។

៥០ ព្រឹត្តិការណ៍សំខាន់ៗដែលបានព្យាករ មានបង្ហាញជូនក្នុងតារាងដែលភ្ជាប់ជាមួយនឹងផែនការនេះ។

01739966

# តារាងកំណត់ពេលវេលាតាមការគ្រោងទុកដែលរួមមានព្រឹត្តិការណ៍សំខាន់ៗ

គម្រោងបញ្ចប់ផែនការ កំណែលើកទី ១២ - ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧




(ង) ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០២

(ច) សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣, ០០៤, ០០៤/០២

(ឆ) សំអាងហេតុពេញលេញសម្រាប់ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/០១ ចេញនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧

(ជ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤